# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ខែកក្កដា-សីហា ឆ្នាំ២០១៧**

**July - August 2017**

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប / Executive summary** | **២** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends** | **៥** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index | ៥ |
| ១.២. វិស័យហិរញ្ញវត្ថុ / Finance | ៦ |
| ១.៣. វិស័យពាណិជ្ជកម្ម / Trade | ៨ |
| ១.៤. ការអនុវត្តថវិកា / Budget execution | ៩ |
| ១.៥. វិស័យវិនិយោគឯកជន / Private investment | ១០ |
| ១.៦. វិស័យទេសចរណ៍ / Tourism | ១១ |
| ១.៧. វិស័យសំណង់ / Construction | ១១ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ / International commodity prices** | **១២** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១២ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១២ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១២ |
| **៣. ឧបសម្ព័ន្ធ** | **១៤** |

## ខ្លឹមសារសង្ខេប

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែកក្កដា ឆ្នាំ២០១៧ បានកើនឡើង ០,៣% ធៀបនឹងខែមុន និងបានកើនឡើង ២,៣% បើធៀបនឹង១ឆ្នាំមុន។

ក្នុងខែកក្កដា សន្ទស្សន៍ថ្លៃនៃក្រុមទំនិញដែលបានកើនឡើងគួរកត់សម្គាល់រួមមាន អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង, សម្លៀកបំពាក់និងស្បែកជើង, ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈ, សុខាភិបាល, និងការកំសាន្តនិងវប្បធម៌។ បើធៀបនឹង១ឆ្នាំមុន សន្ទស្សន៍ថ្លៃក្រុមទំនិញសំខាន់ៗដែលបានកើនឡើងមានដូចជា ភោជនីយដ្ឋាន(កើន៦,៥%) អាហារនិងភេសជ្ជៈគ្មានជាតិស្រវឹង(កើន២,៧%) សម្លៀកបំពាក់(កើន២,៥%) និងការដឹកជញ្ជូន(កើន២,៩%)។ តាមរយៈការធ្វើចំណោលគិតត្រឹមខែធ្នូ ឆ្នាំ២០១៧ អតិផរណាប្រចាំឆ្នាំ(year on year)អាចមានអត្រា ១,៨% ឬអតិផរណាមធ្យមប្រចាំឆ្នាំ(year average)អាចមានអត្រា ២,៩%។

២. *ឥណទាននិងអត្រាការប្រាក់÷* គិតត្រឹមខែកក្កដា ឆ្នាំ២០១៧ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ៦៣.៤៧៩ប៊ីលានរៀល បានកើនឡើង ១,១% ធៀបនឹងខែមុន (កើន ១៤,៧% ធៀបនឹង១ឆ្នាំមុន), ក្នុងនោះឥណទានដល់វិស័យសេវាកម្ម ៣៤.១៩២ប៊ីលានរៀល, ឥណទានដល់វិស័យសំណង់ កសិកម្មនិងឧស្សាហកម្ម ១៦.៣៩៦ប៊ីលានរៀល, និងឥណទានដល់គ្រឹះស្ថានហិរញ្ញវត្ថុ រូបវន្តបុគ្គលនិងផ្សេងៗ ១២.៨៩១ប៊ីលានរៀល។ អត្រាការប្រាក់នៃធនាគារពាណិជ្ជចំពោះកម្ចីជារៀលនិងដុល្លារស្មើនឹង ១៤,៥៣% និង១១,៧៩% គឺបានថយចុះបន្តិចក្នុងរយៈពេល៧ខែដើមឆ្នាំ២០១៧នេះ ជាពិសេសគឺគិតចាប់ពីខែមេសាមកដោយសារការកំណត់ពិដានអត្រាការប្រាក់ឥណទានរបស់ធនាគារជាតិ។

*ការផ្គត់ផ្គង់រូបិយវត្ថុ÷* គិតត្រឹមខែកក្កដា រូបិយវត្ថុទូទៅM2បានកើនដល់ ៦៧.០២០ប៊ីលានរៀល ដោយមានកំណើនជាមធ្យមប្រចាំខែ ២,២% ក្នុងរយៈពេល៧ខែឆ្នាំ២០១៧នេះ (ឆ្នាំ២០១៦មានកំណើនមធ្យមប្រចាំខែ ១,៤%), ក្នុងនោះរូបិយវត្ថុរៀលមានកំណើន ១,៨% និងប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសមានកំណើន ២,៣%។ អត្រារូបិយវត្ថុទូទៅM2ធៀបនឹងផ.ស.ស បានកើនឡើងគួរកត់សម្គាល់ក្នុងរយៈពេល ៨ឆ្នាំចុងក្រោយនេះ ពោលគឺមានអត្រា ០,៣៨ក្នុងឆ្នាំ២០០៩ និងមានអត្រា ០,៧១ក្នុងឆ្នាំ២០១៦, ប៉ុន្តែអត្រានេះនៅមានកម្រិតទាបជាងប្រទេសជិតខាងក្នុងតំបន់។

*អត្រាប្តូរប្រាក់និងទុនបំរុងជារូបិយប័ណ្ណបរទេស÷* គិតត្រឹមខែសីហា អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារស្មើនឹង ៤.០៥០រៀល/ដុល្លារ គឺបានថយចុះបន្តិចធៀបនឹងខែកក្កដាកន្លងទៅ។ ក្នុងរយៈពេល៧ខែដើមឆ្នាំ២០១៧នេះ ធនាគារជាតិនៃកម្ពុជាបានទិញចូលសុទ្ធនូវរូបិយប័ណ្ណដុល្លារអាមេរិកចំនួន ៧១៥លានដុល្លារ។ គិតត្រឹមខែកក្កដា ឆ្នាំ២០១៧ ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធបានកើនដល់ ៨,១ប៊ីលានដុល្លារ។

*ផ្នែកទីផ្សារមូលបត្រ÷* ក្នុងខែសីហា ឆ្នាំ២០១៧ តម្លៃជួញដូរលើទីផ្សារមូលបត្រកម្ពុជា(CSX)មានចំនួន ៦៦០លានរៀល ពោលគឺបានធ្លាក់ចុះមកវិញបន្ទាប់ពីបានលោតឡើងខ្ពស់ក្នុងរយៈពេល២ខែកន្លងទៅ។ អត្រាមូលធនភាវូបនីយកម្មធៀបនឹងGDPរបស់កម្ពុជានៅមានកម្រិតទាបនៅឡើយធៀបនឹងប្រទេសជិតខាងក្នុងតំបន់។ បច្ចុប្បន្ននេះ ក្រុមហ៊ុនដែលកំពុងមានប្រតិបត្តិការអាជីវកម្មមាន ក្រុមហ៊ុនធានាទិញមូលបត្រចំនួន ៦ក្រុមហ៊ុន, ពាណិជ្ជករមូលបត្រចំនួន ១ក្រុមហ៊ុន, ឈ្មួញជើងសារមូលបត្រចំនួន ៣ក្រុមហ៊ុន, ទីប្រឹក្សាវិនិយោគចំនួន ២ក្រុមហ៊ុន, សមភាគីកណ្តាលចំនួន ៤ក្រុមហ៊ុន និងឈ្មួញជើងសារឧបករណ៍និស្សន្ទចំនួន ១០ក្រុមហ៊ុន។

៣. *ការនាំចូល÷* ក្នុងខែកក្កដា ឆ្នាំ២០១៧ ការនាំចូលគិតជាទឹកប្រាក់សរុបមានចំនួន ១.១២៥លានដុល្លារ បានថយចុះ ៣,៥%ធៀបនឹងខែមុន, ក្នុងនោះការនាំចូលទំនិញវាយនភ័ណ្ឌថយចុះ៣,៤% ការនាំចូលគ្រឿងយន្តថយចុះ ២៨,៦% ប៉ុន្តែការនាំចូលបរិក្ខារសំណង់នៅតែបន្តកើនឡើង។ ប្រភពនាំចូលសំខាន់ៗមានដូចជាប្រទេសថៃ ចិន វៀតណាម សិង្ហបុរី និងហុងកុងជាដើម។ *ការនាំចេញ÷* ក្នុងខែកក្កដា ឆ្នាំ២០១៧ ការនាំចេញគិតជាទឹកប្រាក់មានចំនួន ១.០៤៩លានដុល្លារ បានថយចុះ ៧,៥%ធៀបនឹងខែមិថុនាកន្លងទៅ ក្នុងនោះការនាំចេញទំនិញវាយនភ័ណ្ឌនិងស្បែកជើងមាន ៧៨៥លានដុល្លារ បានថយចុះ ៧,០%។ ទីផ្សារគោលដៅនាំចេញសំខាន់ៗនៃកម្ពុជារួមមានសហរដ្ឋអាមេរិក អង់គ្លេស អាល្លឺម៉ង់ ជប៉ុន កាណាដា ចិន វៀតណាម ថៃនិងហូឡង់ជាដើម។ សរុបក្នុងរយៈពេល៧ខែ ឆ្នាំ២០១៧នេះ ការនាំចូលមានចំនួន ៧.៧២៦លានដុល្លារ បានកើនឡើង ៧,៥%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន និងការនាំចេញមានចំនួន ៦.២០៤លានដុល្លារ បានកើនឡើង ៥,៣%។

៤. ក្នុងរយៈពេល៧ខែ ឆ្នាំ២០១៧នេះ ចំណូលក្នុងប្រទេសសរុបអនុវត្តបានចំនួន ៩.៧៤០ប៊ីលានរៀល (ខ្ពស់ជាងច្បាប់ថវិកា ៣,៩%) បានកើនឡើង ១៣,៨%ធៀបនឹងរយៈពេលដូចគ្នានាឆ្នាំមុន ក្នុងនោះចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធបានកើនឡើងរៀងគ្នា ១៤,២% និង១១,០%។ ចំណាយថវិកាសរុបនៅរដ្ឋបាលថ្នាក់ជាតិមានចំនួន ៨.៨០៨ប៊ីលានរៀល(ទាបជាងច្បាប់ថវិកា ១៣,២%) បានកើនឡើង ១៤,៦%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ពោលគឺការអនុវត្តមានលក្ខណៈល្អប្រសើរជាងឆ្នាំកន្លងទៅដោយសារកំណែទម្រង់លើនីតិវិធីចំណាយ និងអ្នកអនុវត្តកាន់តែយល់ជ្រួតជ្រាបពីនីតិវិធីនានា។ ក្នុងរយៈពេល៧ខែឆ្នាំ២០១៧នេះ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ ៣.៣៨៩ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ ៩៣១ប៊ីលានរៀល។

៥. ក្នុងខែសីហា ឆ្នាំ២០១៧នេះ គម្រោងវិនិយោគអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានចំនួន ១០គម្រោង អាចបង្កើតការងារបានប្រមាណ ១២ពាន់នាក់ និងគិតជាទុនវិនិយោគចំនួន ៥៨លានដុល្លារ ក្នុងនោះគម្រោងវិនិយោគទាំងអស់គឺក្នុងវិស័យឧស្សាហកម្ម។ សរុបរយៈពេល៨ខែ ឆ្នាំ២០១៧នេះ ចំនួនគម្រោងវិនិយោគដែលបានអនុញ្ញាតមានចំនួន ៨៧គម្រោង, គិតជាទុនវិនិយោគ ៤.៧៦៥លានដុល្លារ បានកើនឡើង ៨១%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះមានកំណើនខ្ពស់លើការវិនិយោគក្នុងវិស័យកសិកម្ម សេវាកម្មនិងទេសចរណ៍។

៦. ក្នុងខែកក្កដា ឆ្នាំ២០១៧ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិមានប្រមាណ ៤៤៧ពាន់នាក់ បានកើនឡើង ១៨,១% ធៀបនឹងខែមិថុនាកន្លងទៅ និងខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ១៣%។ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិជាទូទៅមានបម្រែបម្រួលជារដូវកាល ដោយមានកម្រិតទាបក្នុងខែឧសភាដោយសារលក្ខណៈអាកាសធាតុ ហើយមានកំណើនឡើងបន្តិចមកវិញក្នុងខែកក្កដានិងសីហា។ ក្នុងរយៈពេល៧ខែ ឆ្នាំ២០១៧នេះ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិសរុបមានចំនួន ៣.១០៩ពាន់នាក់ បានកើនឡើង ១២,៨%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៧. ក្នុងខែកក្កដា ឆ្នាំ២០១៧នេះ សំណើសាងសង់សរុបមាន ៣៥៦គម្រោង បានកើនឡើង ៦៨គម្រោងធៀបនឹងខែមិថុនាកន្លងទៅ។ រយៈពេល៧ខែ ឆ្នាំ២០១៧នេះ សំណើសាងសង់សរុបមាន ១.៨៧៩គម្រោង បានកើនឡើង ៣៧៩គម្រោងធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន, គិតជាតម្លៃសាងសង់សរុប ៥.៣០៧លានដុល្លារ បានកើនឡើង ២៧,៨%, ប៉ុន្តែ

គិតជាផ្ទៃក្រឡាសាងសង់សរុបមាន ៨.២១៣ពាន់ម៉ែត្រការ៉េ បានថយចុះ ៥,៥%។ ទោះជាមានការថយចុះផ្ទៃក្រឡាសាងសង់សរុបក្តី សំណង់នៃផ្នែកទេសចរណ៍នៅតែមានកំណើនខ្ពស់ធៀបនឹងរយៈពេលដូចគ្នាឆ្នាំកន្លងទៅ។

៨. *ថ្លៃប្រេងឆៅ* ក្នុងខែសីហា ឆ្នាំ២០១៧ ថ្លៃប្រេងឆៅជារួមបានកើនឡើងបន្តិចធៀបនឹងខែមុន ប្រេងឆៅក្នុងកិច្ចសន្យាលក់១ខែខាងមុខ ប្រេងBrent ថ្លៃ ៥២,៤ដុល្លារ/ធុង និងប្រេងWTI ថ្លៃ ៤៧,២ដុល្លារ/ធុង។ បរិមាណផលិតកម្មប្រេងពិភពលោកក្នុងខែសីហាស្មើ ៩៦,៧៥លានធុង/ថ្ងៃ បានថយចុះ ០,៤១លានធុង/ថ្ងៃធៀបនឹងខែមុន (កើនឡើង ១,៦៦លានធុង/ថ្ងៃបើធៀបនឹង១ឆ្នាំមុន), ក្នុងនោះបរិមាណផ្គត់ផ្គង់របស់បណ្តាប្រទេសមិនមែនOPEC សរុបស្មើ ៥៧,៦៨លានធុង/ថ្ងៃ បានថយចុះ ០,៣២លានធុង/ថ្ងៃធៀបនឹងខែមុន។ ជារួមក្នុងឆមាសទី១ឆ្នាំ២០១៧នេះ ការផ្គត់ផ្គង់ប្រេងមានកម្រិតខ្ពស់ជាងតម្រូវការ ប៉ុន្តែគម្លាតនេះបានរួមតូចនៅក្នុងត្រីមាសទី២។

*ថ្លៃអង្ករ* ក្នុងខែសីហា ឆ្នាំ២០១៧ *(១)អង្ករកម្ពុជា* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៤៣៥ដុល្លារ/តោន បានកើនឡើង ១០ដុល្លារ/តោនធៀបនឹងខែមុន។ នៅដើមខែសីហានេះ ក្រសួងស្បៀងអាហារនៃប្រទេសបង់ក្លាដែសបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងពាណិជ្ជកម្មក្នុងការទិញអង្ករ ១លានតោនសម្រាប់ ៥ឆ្នាំខាងមុខ។ *(២)អង្ករថៃ* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៣៨៦ដុល្លារ/តោន បានថយចុះ ២៤ដុល្លារ/តោនធៀបនឹងខែមុន, ជារួមថ្លៃអង្ករសនាំចេញថៃបានបន្តថយចុះក្នុងខែសីហានេះដោយសារកង្វះការបញ្ជាទិញថ្មីៗបន្ថែមទៀតពីបរទេស ប៉ុន្តែថ្លៃអង្ករក្រអូបបានកើនឡើងដោយសារការផ្គត់ផ្គង់ក្នុងស្រុកមានកម្រិតទាបក្នុងរដូវកាលនេះ។ *(៣)អង្ករវៀតណាម* អង្ករនាំចេញរបស់វៀតណាម(ខ្ទេច ៥%)ថ្លៃ ៣៩៥ដុល្លារ/តោន បានថយចុះ ១៥ដុល្លារ/តោនធៀបនឹងខែមុន។ មូលហេតុចម្បងនៃការថយចុះថ្លៃនេះគឺដោយសារមានភាពយឺតយ៉ាវនៃតម្រូវការពីទីផ្សារនាំចូលអង្ករសំខាន់ៗនៅអាស៊ី។ យោងតាមរបាយការណ៍ទិដ្ឋភាពទូទៅនៃស្ថានភាពទីផ្សារអង្កររបស់USDA តម្រូវការប្រើប្រាស់អង្ករសម្រាប់ឆ្នាំ២០១៧/១៨នៃពិភពលោកត្រូវបានព្យាករណ៍មានចំនួន ៤៧៩លានតោន និងសម្រាប់ឆ្នាំ២០១៦/១៧ប៉ាន់ស្មានមានចំនួន ៤៨០លានតោន។

*ថ្លៃកៅស៊ូ* ថ្លៃកៅស៊ូធម្មជាតិជារួមបានបន្តកើនឡើងក្នុងខែសីហា ឆ្នាំ២០១៧នេះ, កៅស៊ូស្តង់ដារTSR20 ថ្លៃ ១.៦៣០ដុល្លារ/តោន បានកើនឡើង ៥០ដុល្លារ/តោនធៀបនឹងខែមុន និងកៅស៊ូSGP/MYS ថ្លៃ ១.៨៧០ដុល្លារ/តោន បានកើនឡើង ១១០ដុល្លារ/តោន។ ក្នុងខែសីហានេះ នៅប្រទេសចិនមានការផ្អាកប្រមូលផលកៅស៊ូនៅតាមខេត្តមួយចំនួន ដោយសារមានភ្លៀងធ្លាក់ច្រើន។ តម្រូវការនៃឧស្សាហកម្មផលិតសំបកកង់និងកៅស៊ូរបស់ប្រទេសចិនមានការកើនឡើងក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ។ រយៈពេល៨ខែ ឆ្នាំ២០១៧នេះ បរិមាណកៅស៊ូពិភពលោកផលិតបានមានចំនួន ៨,០៤លានតោន និងបរិមាណប្រើប្រាស់មានចំនួន ៨,៥៤លានតោន ដែលនាំឱ្យមានកង្វះការផ្គត់ផ្គង់ ០,៥០លានតោន។ ក្នុងរយៈពេល៧ខែនេះ កម្ពុជាបាននាំចេញកៅស៊ូ ៧៨,៤ពាន់តោន បានកើនឡើង ៣០,០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំកន្លងទៅ។ តាមការព្យាករណ៍ កម្ពុជាអាចផ្គត់ផ្គង់កៅស៊ូចំនួន ២០១,៦ពាន់តោន និងមានផ្ទៃដាំដុះសរុប ៤៥២,៧ពាន់ហិកតា។

*(ចំពោះសេចក្តីលម្អិតនៃរបាយការណ៍ សូមទាក់ទងផ្ទាល់នាយកដ្ឋានស្ថិតិ នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)*

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)

Construction Approval in Nationwide (0000m2)




Source: Min. LMUC

Tourist Arrivals ('000 persons)



Source: Ministry of Tourism

Total Textile Export (Mn-US$)




Source: Customs and Excise Dept.

Import of Gasoline, Steel, Cement ('000T)




Source: Customs and Excise Dept.

Rice Prices in Bangkok and Vietnam 2003 = 100




Source: MEF & Int.

Crude oil and Gasoline Price, Jan 2003 = 100




Source: MEF & Int.

# អតិផរណា រូបិយវត្ថុ និងទុនបំរុងបរទេស (Inflation, M2 and Foreign Reserve)

**Net Foreign Reserve (Mn US$)**




Source: NBC

**Inflation (Montly)**




Source: NIS

**Inflation (Annual)**




Source: NIS

**Inflation of Main Group Items (monthly)**




Source: NIS

**Inflation of main group Items (Year on Year)**




Source: NIS

**Broad Money M2 (Bn KHR)**




Source: NBC

## អត្រាប្តូរប្រាក់ (Exchange Rate)


















# ធនាគារនិងទីផ្សារមូលបត្រ (Banking and Securities Market)




Source: NBC




Source: NBC




Source: NBC




Source: NBC




Source: NBC




*Source: Cambodia Securities Exchange*

# ការអនុវត្តថវិកា (Budget)

ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០១៦-២០១៧




Source: MEF

ចំណាយការពារសន្តិសុខ និង រដ្ឋបាលស៊ីវិលឆ្នាំ ២០១៦-២០១៧




ចំណូលក្នុងប្រទេស និង ពន្ធលើពាណិជ្ជកម្ម ឆ្នាំ ២០១៦-២០១៧




ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ឆ្នាំ២០១៦-២០១៧




ចំណាយចរន្ត និង វិនិយោគឆ្នាំ ២០១៦-២០១៧




ការដកសាច់ប្រាក់កម្ចីទ្វេភាគី និងពហុភាគី ឆ្នាំ ២០១៦-២០១៧



# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)

**CDC Approval, Fixed Assets and Growth (Mn. $)**




Source: CDC

**CDC Approvals- Fixed Assets by Sectors (Mn. $)**




Source: CDC

**Number of Jobs ('000 person)**




Source: CDC

**Annual Private investment CDC Approval (%)**




Source: MEF

**CDC Approvals, Fixed assets by Sources (Mn. $)**




Source: CDC

**FDI and Direct Investment Abroad, 2011Q1~2017Q1 (Quarterly, USD Mn)**




Source: CEIC

# ទិសដៅពាណិជ្ជកម្ម (Trades)




Source: Customs and Excise Department




Source: Customs and Excise Department




Source: National Bank of Cambodia, NBC, and Customs Dept.




Souce: Customs and Excise Department, MEF
(including foreign currency exports )




Souce: Customs and Excise Department, MEF




Souce: Customs and Excise Department, MEF

********

**រៀបចំដោយ**

**អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ព័ត៌មានផ្សេងៗ សូមទាក់ទង*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧៩១៣, ០៧៧ ៧០៣៤៣៦*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ ព្រឹក និង ២:០០ ដល់ ៥:០០ រសៀល*